NSW GOVERNMENT | Department of Primary Industries



# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## ការគ្រប់គ្រងកាកសំណល់

Virginia Brunton & Jeremy Badgery-Parker, Ourimbah

### កាកសំណល់

ចំនួនសំរាមច្រើនប៉ុណ្ណាដែលលោកអ្នកប្រមូលបាន នៅលើចំការរបស់លោកអ្នក ហើយលោកអ្នកធ្វើអ្វីខ្លះជាមួយនឹងសំរាមទាំងនេះគឺជាការសំខាន់។ ឥឡូវនេះសំរាមត្រូវបានគេហៅថាកាកសំណល់ និងបានពិពណ៌នាថាជាវត្ថុរឹងវត្ថុរាវ ឬជាឧស្ម័នដែលគេបានគ្រវែងចោល ពុំចូលចិត្ត បដិសេធ ឬបោះបង់ចោល។ វាក៏មានសក្តានុពលសំរាប់ប្រើប្រាស់ ឬផលិតឡើងវិញ ដែរ។ កាកសំណល់លើចំការ អាចបណ្តាលឲ្យក្រខ្វក់ដី អាក្រក់មើល ហើយអាចជាគ្រោះថ្នាក់។

កាកសំណល់រួមមានទាំងកំទេចសំណល់ដំណាំ វត្ថុប្លាស្ទិក កញ្ចប់គ្រឿងបរិក្ខារចាស់ៗ និងបាក់បែក សារធាតុគីមី និងធុងដាក់វា និងសម្ភារៈដែលគេប្រើប្រាស់ហើយ ដូចជាដុំរម្ងបំពង់សម្រក់ទឹក និងសំរាមប្លាស្ទិកការពារកុំឲ្យដីស្ងួតជាដើម។ កាកសំណល់គ្រប់ប្រភេទទាំងអស់អាចផ្តល់នូវសត្វចង្រៃដូចជាសត្វល្អិត សត្វចៃ សត្វព្រូន ជម្ងឺ ហើយសូម្បីតែគ្រាប់ពូជនៃរុក្ខជាតិតូចៗឥតប្រយោជន៍ និងទីជំរកលាក់ខ្លួនក្តី ដែលសត្វចង្រៃអាចនឹងយាយីដល់ដំណាំរបស់លោកអ្នក។ ការពុំបានគ្រប់គ្រងកាកសំណល់លើចំការ ក៏បណ្តាលឲ្យមានបញ្ហាច្រើនដែរ មានរួមទាំង:

- ការធ្វើក្រខ្វក់ដី ទឹកក្នុងដី និងប្រភពទឹកឯទៀត
- ការមានគ្រោះថ្នាក់ដល់ទីកន្លែងធ្វើការនៅម្តុំជុំវិញចំការ
- ផ្តល់ជាកន្លែងសំរាប់សត្វពស់ និងពីងពាងដ៏មានគ្រោះថ្នាក់
- ទាក់ទាញសត្វចង្រៃដូចជាសត្វស្លាប កណ្តុរប្រេង និងទន្សាយ ជាដើម
- ការធ្វើឲ្យរាំងស្ទះដល់ការងារចំការរបស់លោកអ្នក
- មើលទៅដូចឥតមានសណ្តាប់ធ្នាប់ និងធ្វើឲ្យអ្នកជិតខាងទើសចិត្ត
- រារាំងពុំឲ្យលោកអ្នកបំពេញផលិតផលដំណាំរបស់លោកអ្នកបានប្រសើរឡើង។

ការងារលើគំនរសំរាមជុំវិញចំការ ធ្វើឲ្យលោកអ្នកចំណាយពេលវេលា និងប្រាក់កាស។ មានវិធីបោះចោល ឬផលិតឡើងវិញសំរាប់កាកសំណល់គ្រប់ប្រភេទ។

យកកំទេចសំណល់ដំណាំចេញ ហើយបោះវាចោលឲ្យបានឆាប់បំផុត តាមលទ្ធភាពធ្វើបានក្រោយពេលរើសចេញ កាត់មែកដំណាំចោល និងច្រូតកាត់ប្រមូលផល។ កុំគរបំណែករុក្ខជាតិជាពំនូកក្បែរទីវាលឲ្យសោះ។ បោះចោលកំទេចសំណល់ដំណាំឲ្យឆ្ងាយផុតពីតំបន់ "ស្អាត" ។ កំទេចសំណល់ដំណាំអាចកប់ចោលបាន ប្រសិនបើត្រូវធ្វើជាបន្ទាន់។ កុំស្តុកវាទុកជាពំនូកឡើយ។ ប្រសិនបើលោកអ្នកយកកំទេចសំណល់ដំណាំធ្វើជាជីអំពុកនៅលើទីតាំង ចូរកាត់វាជាចំណែកតូចៗដើម្បីបង្រួមទំហំ និងធ្វើឲ្យវាឆាប់រលួយ។



> *" ត្រូវឲ្យកន្លែងដាំដុះបានស្អាតជាប្រចាំ ហើយត្រូវយកចេញកំទេចសំណល់ដំណាំទាំងអស់ ឬត្រូវកប់វាក្នុងដី មុនពេលដាំដំណាំថ្មី "*

កាកសំណល់ក្រដាស និងក្រដាសកាតតុង វត្ថុប្លាស្ទិកមួយចំនួន និងកែវកញ្ចក់ទាំងអស់អាចប្រមូលសំរាប់ផលិតឡើងវិញបាន។ ធ្វើឲ្យចំនួនសំរាមដែលអនុញ្ញាតឲ្យមាននៅលើដីកម្មសិទ្ធិ មាននៅសល់តិចបំផុតមុននឹងបោះវាចោល។ ត្រូវធ្វើឲ្យប្រាកដច្បាស់ថា លោកអ្នកមានទីកន្លែងដាក់លាក់ជាប្រចាំ – នៅឆ្ងាយពីដំណាំ – ដែលអាចទុកដាក់សម្ភារៈទាំងអស់ដោយរៀបរយ រហូតដល់ពេលបោះវាចោល។ ធុងដាក់កាកសំណល់ធំ (ឧទាហរណ៍ ឡាំង

ធំបើកមាត់សម្រាប់ផ្ទុកលើរថយន្ត) ដែលត្រូវបានយកសំរាមចេញទាំងអស់ ដោយទៀងទាត់ គឺជាការអនុវត្តន៍មួយដ៏ល្អ។

> *“ កុំទុកសំរាម និងសម្ភារៈដែលបានប្រើប្រាស់ហើយ*
> *នៅក្នុងតំបន់បន្ទុយគ្រោះថ្នាក់*
> *ជុំវិញកន្លែងផលិតភោគផលឡើយ”*

កិច្ចបំរើសំរាប់ប្រមូលវត្ថុធំៗទាំងមូល មានផ្តល់ជូនដោយសាលាក្រុងរបស់លោកអ្នក។ លោកអ្នកអាចរៀបចំឲ្យគេប្រមូលយកសម្ភារៈ ពេលណាលោកអ្នករៀបចំទុកដាក់វានៅកន្លែងដែលគេអាចចូលដល់បាន។ លោកអ្នកអាចជួលឡាំងធំបើកមាត់ដែលសម្រាប់ផ្ទុកលើរថយន្តពីក្រុមហ៊ុន ដែលគេនឹងយកកាកសំណល់របស់លោកអ្នកទៅបោះចោលដោយគិតថ្លៃឈ្នួល។

លោកអ្នកអាចបោះចោលធុងដាក់សារធាតុគីមីដែលប្រើរួចហើយ តាមរយៈ DrumMuster (កន្លែងប្រមូល និងផលិតធុងដាក់សារធាតុគីមីឡើងវិញ) ដែលធ្វើប្រតិបត្តិការនៅគ្រប់រដ្ឋ។ ដើម្បីទទួលបានពត៌មានពិស្តារអំពីការប្រមូលយក សូមទំនាក់ទំនងមក DrumMuster តាមទូរស័ព្ទ លេខ (02) 6230 6712 ឬវិបសាយ
http://www.drummuster.com.au/

នេះគឺជាការខុសច្បាប់ដែលដុតសំរាមណាមួយចោលនៅតំបន់ខាងក្នុង និងជុំវិញជាយក្រុងភាគច្រើន។ សំរាមទាំងនេះត្រូវបោះចោលឲ្យត្រូវតាមច្បាប់។ នៅទីជនបទមួយចំនួន គេអាចដុតចោលសំរាមដែលអាចឆាបឆេះ ការនេះពុំរាប់បញ្ចូលវត្ថុប្លាស្ទិកឡើយ។ សូមឆែកមើលជាមួយសាលាក្រុងរបស់លោកអ្នកជាមុនសិន។ ការផាកពិន័យមានកំរិតខ្ពស់ ចំពោះការបោះចោលកាកសំណល់ដោយខុសច្បាប់។



ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពី រក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រងសត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយនេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្តី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្តីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើ មានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារសមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្តល់ឱវាទឯករាជ្យសំរាប់អ្នកប្រើប្រាស់។

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT12/24533

Horticulture Australia

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបានទទួលការផ្គត់ផ្គង់ប្រាក់មួយ ចំណែកពីគំរោងដែលទទួលប្រាក់ឧបត្ថម្ភរបស់ HAL
អង្គការដំណាំវប្បកម្មអូស្ត្រាលី): *ការដោះស្រាយអំពីគុណភាពនិងសុវត្ថិភាពនៃផលិតផលជាមួយអ្នកដាំដុះនៃឧស្សាហកម្មបន្លែដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស*
ការផ្តើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្ម បន្លែ។